ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ១២៦ ប្រក កសក

# ប្រកាស
# ស្តីពី
# ការបង្កើតតំបន់គ្រប់គ្រងនិងអភិរក្សជីវចម្រុះជលផលទន្លេមេគង្គ

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៥/២៤០ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៥ ស្តីពីការបង្កើតសហគមន៍នេសាទ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្មឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ២៥ អនក្រ.បក ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៧ ស្តីពីការគ្រប់គ្រងសហគមន៍នេសាទ
- បានឃើញអនុក្រឹត្យលេខ៥៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៦ ស្តីពីការធ្វើពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វនិងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់

- បានឃើញអនុក្រឹត្យលេខ១២៣ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្តីពីការកំណត់ប្រភេទផល ផលិតផលជលផលដែលកំពុងរងគ្រោះថ្នាក់
- បានឃើញអនុក្រឹត្យលេខ១៥៥ អនក្រ.បក ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១២ ស្តីពីការបង្កើតតំបន់គ្រប់គ្រងនិងការពារសត្វផ្សោតទន្លេមេគង្គ
- បានឃើញប្រកាសលេខ៩៧១ ប្រក.កសក ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីវិធានការការពារប្រភេទធនធានជលផលដែលកំពុងរងគ្រោះថ្នាក់
- យោងតាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាប្រធានរដ្ឋបាលជលផល

## សម្រេច

**ប្រការ១.-**

ប្រកាសនេះមានគោលបំណងបង្កើតតំបន់គ្រប់គ្រងនិងអភិរក្សជីវចម្រុះជលផលទន្លេមេគង្គ ស្ថិតក្នុងភូមិសាស្ត្រស្រុកសំបូរ ខេត្តក្រចេះ និងស្រុកសៀមបូក ខេត្តស្ទឹងត្រែង ដើម្បីការពារនិងអភិរក្សធនធានជលផលប្រកបដោយនិរន្តរភាព ស្របតាមគោលនយោបាយវិស័យជលផលជាតិ។

**ប្រការ២.-**

ប្រកាសនេះមានគោលដៅ ៖

- គ្រប់គ្រងនិងអភិរក្សជីវចម្រុះជលផលទន្លេមេគង្គឲ្យមានប្រសិទ្ធភាពខ្ពស់
- សិក្សាស្រាវជ្រាវនិងកំណត់តំបន់គ្រប់គ្រងទៅតាមមុខងារនៃប្រព័ន្ធអេកូឡូស៊ីនិងការប្រើប្រាស់របស់សហគមន៍មូលដ្ឋាន
- សិក្សាស្រាវជ្រាវបច្ចេកទេស អង្កេតតាមដានលក្ខណៈជីវសាស្ត្រ និងបម្រែបម្រួលបរិស្ថាន
- គាំទ្រការអភិវឌ្ឍអេកូទេសចរណ៍របស់សហគមន៍មូលដ្ឋាន ដែលមិនបង្កផលប៉ះពាល់ជាអវិជ្ជមានដល់និរន្តរភាពជីវចម្រុះជលផល ដើម្បីការអភិវឌ្ឍសេដ្ឋកិច្ចសង្គមជនបទនិងការកាត់បន្ថយភាពក្រីក្រ។

**ប្រការ៣.-**

តំបន់គ្រប់គ្រងនិងអភិរក្សជីវចម្រុះជលផលទន្លេមេគង្គ រួមមាន អន្លង់ជ្រៅៗ តំបន់ទឹកជ្រោះ នាទីព្រៃលិចទឹក ទំនាបលិចទឹក និងប្រភេទព្រៃលិចទឹកនៅអមតាមដងទន្លេដែលមានសារសំខាន់សម្រាប់ជាជម្រកពងកូន និងកន្លែងផ្តល់ចំណីដល់មច្ឆជាតិនិងវារីសត្វដទៃទៀត។

**ប្រការ៤.-**

តំបន់គ្រប់គ្រងនិងអភិរក្សជីវចម្រុះជលផលត្រូវបានបែងចែកជាអាទិ៍ កន្លែងអភិរក្សជលផល កន្លែងនេសាទគ្រួសារ កន្លែងនេសាទសហគមន៍ នាទីព្រៃលិចទឹក ទំនាបលិចទឹកក្នុងរដូវជំនន់ឡើងដែលប្រជាពលរដ្ឋមានទម្លាប់ប្រកបមុខរបរកសិកម្ម ប្រភេទព្រៃលិចទឹកនៅអមតាមដងទន្លេ តំបន់អេកូទេសចរណ៍ និងផ្លូវចរាចរណ៍សម្រាប់ប្រើប្រាស់របស់ប្រជាពលរដ្ឋ។

ផែនទីបែងចែកតំបន់គ្រប់គ្រងនិងអភិរក្សជីវចម្រុះជលផលទន្លេមេគង្គដែលមានចែងក្នុងវាក្យខណ្ឌទី១ខាងលើត្រូវរៀបចំដោយរដ្ឋបាលជលផលបន្ទាប់ពីមានការពិគ្រោះយោបល់ជាមួយស្ថាប័ននិងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ។

**ប្រការ៥.-**

តំបន់គ្រប់គ្រងនិងអភិរក្សជីវចម្រុះជលផលទន្លេមេគង្គលាតសន្ធឹងចាប់ពីកន្ទុយកោះច្បារ ភូមិកោះច្បារ ឃុំកោះខ្ញែរ ស្រុកសំបូរ ខេត្តក្រចេះ រហូតទៅដល់ក្បាលកោះព្រះ ភូមិកោះព្រះ ឃុំកោះព្រះ ស្រុកសៀមបូក ខេត្តស្ទឹងត្រែង មានប្រវែង៥៦ (ហាសិបប្រាំមួយ)គីឡូម៉ែត្រ ក្រឡាផ្ទៃ២០.៥៧៧ (ម្ភៃពាន់ប្រាំរយចិតសិបប្រាំពីរ) ហិកតា និងមាននិយាមកាដូចខាងក្រោម៖

A(៦០៩៥១១-១៤២៥៧៦១) B (៦១៥៧៤១-១៤៣៦៧៣៥)
C (៦១៨០២៣-១៤៤៥៧០២) D (៦១៤១៧៩-១៤៥៧៣៩៦)
E(៦០៥៨០៥-១៤៦៤៧៦៩) F (៦០៥២២១-១៤៧៥៣៥២)
G (៥៩៩៩៣២-១៤៧៥៣៦៦) H (៦០០១៥៣-១៤៦៥៨៣៥)
I(៦០៣៩៨៤-១៤៦០៤៦៥) J (៦០៩៩២៤-១៤៥៣៩៥៣)
K(៦០៨១២៤-១៤៤៨៣១៥) L (៦០៤៧៦៨-១៤៣៨០២៩) និង
M(៦០៣៤៦៩-១៤២៥៧៩៣)

ផែនទីតំបន់គ្រប់គ្រងនិងអភិរក្សជីវចម្រុះជលផលទន្លេមេគង្គមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ៦.-**

ការគ្រប់គ្រងតំបន់គ្រប់គ្រងនិងអភិរក្សជីវចម្រុះជលផលទន្លេមេគង្គ ដូចមានចែងក្នុងប្រការ៥ ខាងលើជាសមត្ថកិច្ចរបស់រដ្ឋបាលជលផលដោយសហការជាមួយស្ថាប័ននិងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ។

រដ្ឋបាលជលផលត្រូវមានភារកិច្ចសំខាន់ៗ ដូចខាងក្រោម៖

- រៀបចំគណៈកម្មការទទួលខុសត្រូវលើតំបន់គ្រប់គ្រងនិងអភិរក្សជីវចម្រុះជលផលទន្លេមេគង្គ
- រៀបចំនិងអនុវត្តផែនការគ្រប់គ្រង
- រៀបចំក្រុមឆ្មាំយាមប្រចាំការនៅតាមទីតាំងសំខាន់ៗ
- កំណត់ព្រំប្រទល់និងបោះបង្គោលនៃតំបន់គ្រប់គ្រងនិងអភិរក្សជីវចម្រុះជលផលទន្លេមេគង្គ
- សិក្សាស្រាវជ្រាវនិងកំណត់តំបន់ទៅតាមមុខងារនៃប្រព័ន្ធអេកូឡូស៊ីនិងការប្រើប្រាស់របស់សហគមន៍មូលដ្ឋាន
- សិក្សាស្រាវជ្រាវបច្ចេកទេស អង្កេតតាមដានលក្ខណៈជីវសាស្ត្រ និងបម្រែបម្រួលបរិស្ថាន
- បង្កើតហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការងារគ្រប់គ្រងដូចជាស្នាក់ការត្រួតពិនិត្យស្នាក់ការស្រាវជ្រាវ សម្ភារមធ្យោបាយត្រួតពិនិត្យនិងសម្ភារការងាររដ្ឋបាលបម្រើឲ្យការងារគ្រប់គ្រងនិងអភិរក្ស
- រៀបចំយន្តការអធិការកិច្ច
- ផ្សព្វផ្សាយជាសាធារណៈអំពីតំបន់គ្រប់គ្រងនិងការអភិរក្សជីវចម្រុះជលផលទន្លេមេគង្គព្រមទាំងផ្សព្វផ្សាយច្បាប់ស្តីពីជលផល និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធដល់ប្រជាពលរដ្ឋ
- សហការជាមួយដៃគូអភិវឌ្ឍន៍និងកៀរគរជំនួយពីដៃគូអភិវឌ្ឍន៍ អង្គការជាតិ អង្គការអន្តរជាតិ និងសប្បុរសជននានា ដើម្បីគាំទ្រផ្តល់មូលនិធិទ្រទ្រង់សកម្មភាពគ្រប់គ្រងនិងអភិរក្សជីវចម្រុះជលផលទន្លេមេគង្គ
- រៀបចំទ្រទ្រង់និងកែលម្អជីវភាពរស់នៅដល់សហគមន៍មូលដ្ឋានសំដៅបន្ថយនូវសម្ពាធនៃការប្រើប្រាស់ធនធានធម្មជាតិ។

**ប្រការ៧.-**

ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់គ្រប់គ្រងនិងអភិរក្សជីវចម្រុះជលផលទន្លេមេគង្គមានសិទ្ធិប្រើប្រាស់ជាលក្ខណៈប្រពៃណីលើសកម្មភាពដូចខាងក្រោម លើកលែងក្នុងកន្លែងអភិរក្សជលផល៖

- ការនេសាទជាលក្ខណៈប្រពៃណី
- ការប្រើប្រាស់ដីធ្លីសម្រាប់ប្រកបរបរកសិកម្មជាលក្ខណៈគ្រួសារ។

**ប្រការ៨.-**

ជនណាដែលប្រព្រឹត្តផ្ទុយនឹងប្រកាសនេះ ត្រូវផ្ដន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ៩.-**

ប្រកាសឬសេចក្ដីសម្រេចទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ១០.-**

អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធានរដ្ឋបាលជលផល ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ២០១៣

រដ្ឋមន្ត្រី

ជ័ន្ទ.សារុន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងការពារជាតិ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងបរិស្ថាន
- ក្រសួងយុត្តិធម៌
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្ដម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលាខេត្តពាក់ព័ន្ធ
- ដូចប្រការ១០
- ឯកសារ កាលប្បវត្តិ